**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

លេខ : ០៧១ / [illegible] /២០០៥

រាជធានីភ្នំពេញ. ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៥

# ប្រកាស

## ស្តីពីការចេញប័ណ្ណអាវុធខ្លី ក្នុងកងយោធពលខេមរភូមិន្ទ

*****

## សមារដ្ឋមន្ត្រីក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥ ចុះថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០០៥ ប្រកាសអោយប្រើច្បាប់ ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួល តួនាទី ភារៈកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រង និងការ ត្រួតពិនិត្យ ការនាំចូល ការផលិត ការលក់ ការទិញដូរ ការចែកចាយនិងការប្រើប្រាស់អាវុធជាតិផ្ទុះគ្រប់ប្រភេទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ

- យោងប្រកាសអន្តរក្រសួង លេខ ០០១/២០០៥ ប្រ.ក ចុះថ្ងៃទី ០៩ ខែមិនា ឆ្នាំ ២០០៥ ស្តីពីការកែតម្រូវប្រកាសអន្តរក្រសួងមហាផ្ទៃ-ក្រសួងការពារជាតិ លេខ ៧៩២ ប្រ.ក ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ១៩៩៩
- បានឃើញសេចក្តីសំរេចលេខ ០៤២/០៤ ស.ស.រ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការចេញប័ណ្ណអាវុធខ្លី ផ្លាកលេខសំគាល់សំភារៈសឹក ប័ណ្ណបើកបរ ប័ណ្ណសំគាល់ និងផ្លាកលេខយានយន្តគ្រប់ប្រភេទរបស់ក្រសួងការពារជាតិ ។
- ដើម្បីធានាដល់ការគ្រប់គ្រងអាវុធខ្លីគ្រប់ប្រភេទក្នុងកងយោធពលខេមរភូមិន្ទ អោយមានសណ្តាប់ធ្នាប់របៀបរៀបរយនិងការប្រើប្រាស់បានត្រឹមត្រូវតាមច្បាប់កំណត់ ។

## សម្រេច

**ប្រការ ១ : កំណត់ទូទៅ**

១.១- ប័ណ្ណអាវុធខ្លីរបស់កងយោធពលខេមរភូមិន្ទ ដែលបានចេញឱ្យប្រើប្រាស់កន្លងមក ដោយអត្តបញ្ជាការប្តូរមកប្រើប្រាស់ប័ណ្ណអាវុធខ្លីថ្មី ។

១.២- អាវុធខ្លីគ្រប់ប្រភេទ ត្រូវបានផ្តល់ប័ណ្ណប្រើប្រាស់ គឺជាអាវុធខ្លី ដែលជាទ្រព្យសម្បត្តិរបស់កងយោធពលខេមរភូមិន្ទ ហើយត្រូវបានចំពាក់ និងចុះបញ្ជីគ្រប់គ្រងដោយក្រសួងការពារជាតិ ។

១.៣- អាវុធខ្លី ដែលត្រូវបានផ្តល់ប័ណ្ណប្រើប្រាស់របស់កងយោធពលខេមរភូមិន្ទ ត្រូវបានកំណត់ប្រភេទដូចខាងក្រោម :

- ប្រភេទទី ១ : អាវុធខ្លីប្រើប្រាស់ផ្ទាល់ខ្លួន
- ប្រភេទទី ២ : អាវុធខ្លីប្រើប្រាស់ក្នុងពេលប្រតិបត្តិការ ឬ បេសកកម្ម ( រួម )

**ប្រការ ២ : រូបភាពប័ណ្ណអាវុធខ្លី :**

២.១-ប័ណ្ណអាវុធខ្លី ( ផ្ទាល់ខ្លួន) មានរាងបួនជ្រុងទ្រវែង ពីមុខមានពណ៌ផ្កាឈូក មានផ្កាភ្ញីព័ទ្ធជុំវិញមានសរសេរជាអក្សរខ្មែរ រូបសញ្ញាក្រសួងការពារជាតិ នៅខាងលើផ្នែកខាងស្តាំ ខាងក្រោមរូបសញ្ញា មានកន្លែងបិទរូបថត ២x៣ ( រូបថតអ្នកប្រើប្រាស់អាវុធខ្លី ) និងពីជ្រុងម្ខាងទៅជ្រុងម្ខាង មានរូបទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា។ ផ្នែកខាងក្រោយប័ណ្ណ មានពណ៌ផ្កាឈូកព័ទ្ធជុំវិញទៅដោយគំនូសពណ៌ក្រហម មានសរសេរជាអក្សរខ្មែរ ។

២.២- ប័ណ្ណអាវុធខ្លី (រួម) មានរាងបួនជ្រុងទ្រវែង ពីមុខមានពណ៌បៃតង មានផ្កាភ្ញីព័ទ្ធជុំវិញមានសរសេរជាអក្សរខ្មែរ រូបសញ្ញាក្រសួងការពារជាតិនៅខាងលើផ្នែកខាងស្តាំ និងពីជ្រុងម្ខាងទៅជ្រុងម្ខាង មានរូបទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។ ផ្នែកខាងក្រោយប័ណ្ណ មានពណ៌បៃតងព័ទ្ធជុំវិញដោយគំនូសពណ៌ទឹកប៊ិច មានសរសេរជាអក្សរខ្មែរ ។

២.៣- ប័ណ្ណសំគាល់សិទ្ធិប្រើប្រាស់អាវុធខ្លី មានបញ្ជាក់អំពីប្រភេទអាវុធ លេខអាវុធ ចំនួនគ្រាប់ និងលក្ខខ័ណ្ឌដែលត្រូវគោរព ។

**ប្រការ ៣ : លក្ខខ័ណ្ឌប្រើប្រាស់**

៣.១- ការចេញប័ណ្ណ និងអនុញ្ញាតអោយប្រើប្រាស់ប័ណ្ណអាវុធខ្លី ចំពោះតែអាវុធខ្លីដូចដែលបានកំណត់ក្នុងប្រការ ១ ។

៣.២- គ្រប់ស្ថាប័នកងឯកភាពត្រូវបំពេញបែបបទ ដើម្បីស្នើសុំប័ណ្ណអាវុធខ្លី តាមឋានានុក្រម និងតាមការណែនាំ របស់សមត្ថកិច្ចជំនាញទទួលបន្ទុក ដោយមានភ្ជាប់មកជាមួយនូវបញ្ជីរៀបរាប់លំអិត អំពីបរិមាណ គុណភាព និងប្រភពចំពាក់អោយបានច្បាស់លាស់ ។

៣.៣- ចំពោះអាវុធខ្លីដែលខូចខាតមិនអាចប្រើប្រាស់បាន ដែលស្ថិតនៅក្នុងបញ្ជីគ្រប់គ្រង និងពុំទាន់មានសេចក្តីសំរេចថ្នាក់លើកាត់ចេញពីបញ្ជីគ្រប់គ្រង គឺត្រូវបានរក្សាទុកក្នុងបញ្ជី និងបញ្ចូលក្នុងស្ថិតិដែលត្រូវស្នើសុំប័ណ្ណប្រើប្រាស់ថ្មី រហូតដល់ពេលមានសេចក្តីសំរេចពីក្រសួងការពារជាតិ ។

- ចំពោះអាវុធខ្លីដែលធ្វើការផ្លាស់ប្តូរគ្រឿងបន្លាស់ ឬ ធ្វើអោយបាត់ប័ណ្ណអាវុធថ្មីនេះ ត្រូវធ្វើបែបបទដើម្បីសុំកែសំរួលប័ណ្ណថ្មីទៀត សំរាប់ប្រើប្រាស់អោយបានត្រឹមត្រូវតាមស្ថានភាពជាក់ស្តែងរបស់អាវុធខ្លី ។

- អាវុធខ្លីរបស់កងយោធពលខេមរភូមិន្ទជាមធ្យោបាយយកតាមខ្លួន និងការពារសុវត្ថិភាព សន្តិសុខផ្ទាល់ខ្លួន ក្នុងពេលប្រតិបត្តិការ ឬ បំពេញបេសកកម្ម និងបំរើការងារ ។

- កងយោធពលខេមរភូមិន្ទអាចអនុញ្ញាតអោយប្រើប្រាស់អាវុធខ្លីយកតាមខ្លួនមួយនាក់ មួយដើមជាលក្ខណៈផ្ទាល់ខ្លួន ចាប់ពីថ្នាក់វរៈសេនីយ៍ឯកឡើងទៅ ។

- ប័ណ្ណសំគាល់សិទ្ធិប្រើប្រាស់អាវុធខ្លី ( រួម ) របស់ស្ថាប័នកងឯកភាព ពេលចប់ប្រតិបត្តិការ ឬ បេសកកម្ម ( ត្រូវភ្ជាប់មកជាមួយលិខិតបេសកកម្ម ) ត្រូវយកមករក្សាទុកក្នុងស្ថាប័នកងឯកភាពសាម៉ីវិញ ។

- ករណីបាត់អាវុធខ្លី គ្រាប់ ដែលបាននិងកំពុងកាន់កាប់ប្រើប្រាស់ ហើយការបាត់នោះកើតឡើងនៅក្រៅអង្គភាព ត្រូវរាយការណ៍មិនលើសពី ២៤ ( ម្ភៃបួន ) ម៉ោង ក្រោយពេលដឹងថាបាត់ ដល់សមត្ថកិច្ច ឬ រដ្ឋអំណាចនៅកន្លែងដែលបាត់ ហើយត្រូវមានសាក្សីដឹងឮម្នាក់ ឬ ពីរនាក់ទៅជាមួយផងនៅពេលរាយការណ៍ ។ ក្នុងករណីគ្មានសាក្សីសមត្ថកិច្ចនៅកន្លែងកើតហេតុ ត្រូវចុះត្រួតពិនិត្យនិងធ្វើកំណត់ហេតុដល់ទីកន្លែងដែលបាត់ ។

- របាយការណ៍ស្តីពីការបាត់អាវុធខ្លី និងគ្រាប់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយបញ្ជាក់លំអិតទាក់ទិននឹងប្រភេទអាវុធខ្លី និងគ្រាប់ លេខចុះបញ្ជី ព្រមទាំងមូលហេតុ និងកាលៈទេសៈនៃការបាត់ ។

**ប្រការ ៤ : សមត្ថកិច្ចគ្រប់គ្រង ការចេញប័ណ្ណអាវុធខ្លី និងការលើកលែង**

៤.១- គ្រប់ស្ថាប័នកងឯកភាព ត្រូវបំពេញបែបបទស្នើសុំប័ណ្ណអាវុធខ្លី តាមសមត្ថកិច្ចជំនាញ និងបានការទទួលស្គាល់របស់មេបញ្ជាការស្ថាប័នកងឯកភាព ឆ្លងតាមឋានានុក្រមមកក្រសួងការពារជាតិ ដើម្បីពិនិត្យផ្តល់ជូនសំរាប់ប្រើប្រាស់ ។ គំរោងស្នើសុំត្រូវភ្ជាប់មកជាមួយនូវបញ្ជីស្ថិតិ ដូចមានចែងក្នុងប្រការ ៣ ។

៤.២- អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស មានភារៈកិច្ចពិនិត្យលើគំរោងស្នើសុំរបស់បណ្តាស្ថាប័នកងឯកភាព នឹងសំរេចចេញប័ណ្ណអាវុធខ្លីអោយដល់ស្ថាប័នកងឯកភាពសំរាប់យកទៅប្រើប្រាស់ ។

៤.៣- គ្រប់ស្ថាប័នកងឯកភាពក្នុងកងយោធពលខេមរភូមិន្ទ ត្រូវធ្វើបែបបទស្នើសុំប័ណ្ណអាវុធខ្លីថ្មី ដើម្បីបំពាក់អោយកងយោធពលខេមរភូមិន្ទដូចក្នុងប្រការ ១ អោយបានចប់សព្វគ្រប់នូវដំណាច់ខែ តុលា ឆ្នាំ ២០០៥ យ៉ាងយូរបំផុត ។

៤.៤- ប័ណ្ណអាវុធខ្លីចាស់ដែលចេញអោយប្រើប្រាស់ ដោយអគ្គបញ្ជាការបានចេញ ត្រូវអស់សុពលភាពនៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៥ ។

**ប្រការ ៥** : ជនណាប្រើប្រាស់ប័ណ្ណអាវុធខ្លីក្លែងក្លាយ និងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៦** : ការត្រួតពិនិត្យលើការប្រើប្រាស់អាវុធខ្លី របស់កងយោធពលខេមរភូមិន្ទ ជាភារៈកិច្ចរបស់កងរាជ - អាវុធហត្ថ ។

**ប្រការ ៧** : ខ្លឹមសារនៃសេចក្តីណែនាំ សេចក្តីកំណត់ទាំងឡាយ ដែលផ្ទុយនិងខ្លឹមសារនៃសេចក្តីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៨** : អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស មេបញ្ជាការកងទ័ពជើងគោក មេបញ្ជាការកងទ័ពជើងទឹក មេបញ្ជាការកងទ័ពជើងអាកាស មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គនាយក នាយកប្រធាន មេបញ្ជាការស្ថាប័នកងឯកភាពចំណុះក្រសួងការពារជាតិ និងអគ្គបញ្ជាការដ្ឋាន ត្រូវមានវិធានការផ្សព្វផ្សាយនិងអនុវត្តប្រកាសនេះ អោយបានម៉ឺងម៉ាត់និងមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ផ្ញើជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៨
  " ដើម្បីអនុវត្ត "
- ឯកសារ កាលប្បវត្តិ

នាយឧ.ផ្កាយមាស៥ ទៀ-បាញ់ នាយឧ.ផ្កាយមាស៤.ញឹក-ប៊ុនឆៃ